ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ELECTRICITE DU CAMBODGE

អគ្គិសនីកម្ពុជា
លេខ: ៣១៩១ សជណ.អក.ទប

# សេចក្តីជូនដំណឹង
## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជា សូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើស**បុគ្គលិក ចំនួន ០៦ រូប** ដើម្បីចូលបម្រើការងារនៅ អគ្គិសនីកំពត នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម :

*-**លក្ខណៈសម្បត្តិបេក្ខជន** :

**១. បុគ្គលិករដ្ឋបាល** ចំនួន ០១ រូប :
- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឡើងទៅ

**២. បុគ្គលិកគ្រប់គ្រងកិច្ចសន្យា និងបំណុល** សរុបចំនួន ០២ រូប **(សម្រាប់សាខាកំពង់ត្រាច ចំនួន ០១ រូប)** :
- បេក្ខជនទាំងពីរភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា បរិញ្ញាបត្រព័ត៌មានវិទ្យា ឡើងទៅ

**៣. ភ្នាក់ងារដំឡើង ជួសជុល និងថែទាំបណ្តាញ, ភ្នាក់ងារស្រង់ថាមពល, ភ្នាក់ងារអន្តរាគមន៍ បន្តចរន្ត កាត់ និងភ្ជាប់ចរន្ត សាខាកំពង់ត្រាច** សរុបចំនួន ០៣ រូប :
- បេក្ខជនភេទប្រុស, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ
- បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.១ ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន ៩០%
- កម្រិតជំនាញ : បញ្ចប់ការសិក្សា សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនី ឡើងទៅ

*- **បញ្ជាក់** : ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺផ្តល់អទិភាពជូន
- ជនពិការ
- បេក្ខនារីគ្រប់ខេត្ត-ក្រុងនិងបេក្ខជន មានអាសយដ្ឋានស្ថិតនៅខេត្តសាមី ។

*- **ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅអគ្គិសនីកម្ពុជាបេក្ខជនត្រូវទាញយក(Download) ដោយផ្ទាល់ពីក្នុងគេហទំព័ររបស់អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុចព័ត៌មានវិជ្ជាជីវៈ ដោយចុចលើពាក្យសុំចូលប្រឡងដើម្បីបម្រើការងារនៅ អគ្គិសនីកម្ពុជា ។**

*- **បេក្ខជនត្រូវបំពេញពាក្យសុំចូលបម្រើការងារ និងត្រូវអញ្ជើញមកដាក់ពាក្យប្រឡងដោយផ្ទាល់ខ្លួន និងភ្ជាប់មកជាមួយនូវអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ច្បាប់ដើមមកជាមួយ ។ ករណី បេក្ខជនមិនបានអញ្ជើញមកដាក់ពាក្យដោយផ្ទាល់ទេ អគ្គិសនីកម្ពុជា មិនទទួលពាក្យជូនឡើយ ។**

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលប្រឡងដើម្បីបម្រើការងារ នៅអគ្គិសនីកម្ពុជា | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - កិច្ចសន្យា សម្រាប់បំពេញពាក្យសុំចូលបម្រើការងារ និងកិច្ចសន្យាការងារ | ចំនួន ០១ ច្បាប់ |
| - សលាកប័ត្របេក្ខជន | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ (TRANSCRIPT) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ដើម និងច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន | ចំនួន ០១ ច្បាប់ |

*- **ចំពោះបេបបទមួយចំនួនទៀត ដូចមានចែងក្នុងឧបសម្ព័ន្ធI នៃលក្ខន្តិកៈបុគ្គលិកអគ្គិសនីកម្ពុជា បេក្ខជនប្រឡងជាប់ មានកាតព្វកិច្ចបំពេញបន្ថែម ។**

*- **ទីកន្លែងទទួលពាក្យ** : **នៅអគារ B ជាន់ទី១ ការិយាល័យបុគ្គលិក នៃអគ្គិសនីកម្ពុជា**

ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០ ។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល ទីស្នាក់ការកណ្ដាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ជ. **រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**អគ្គនាយកអគ្គិសនីកម្ពុជា**

**អគ្គនាយករង**

**អេខ_គន្ធា**

**បញ្ជាក់**

- សេចក្ដីជូនដំណឹងនេះ ធ្វើការផ្សព្វផ្សាយជាផ្លូវការតាមរយៈគេហទំព័ររបស់ អគ្គិសនីកម្ពុជា គឺ : www.EDC.com.kh ត្រង់ចំណុច " ព័ត៌មានវិជ្ជាជីវៈ " ។

អគ្គិសនីកម្ពុជា: #២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៧២៣ ៩៧១ - ៧២៤ ៧៧១